**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ..ធ៣៨..០១៩...៣៩១..ប្រ.ក.

# ប្រកាស
# ស្តីពី
# លក្ខណៈសម្គាល់នៃធនប័ត្រអនុស្សាវរីយ៍ ប្រភេទ ១៥០០០ រៀល

អនុលោមទៅតាមអនុក្រឹត្យលេខ ១៥៣ អនក្រ.បក របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០១៩ ស្តីពីការចេញផ្សាយធនប័ត្រអនុស្សាវរីយ៍ ប្រភេទ ១៥០០០ រៀល ក្នុងព្រះរាជាណាចក្រកម្ពុជា ធនាគារជាតិនៃកម្ពុជា សូមប្រកាសផ្សាយជាសាធារណៈនូវលក្ខណៈសម្គាល់នៃធនប័ត្រអនុស្សាវរីយ៍នេះ មានដូចខាងក្រោម ៖

**ក- លក្ខណៈទូទៅ ៖**

- ទំហំធនប័ត្រ : បណ្តោយ ១៧០ មម ទទឹង ៧៥ មម
- ពណ៌ចម្បងគឺពណ៌ស្វាយ ពណ៌ស៊ីជំពូ និងពណ៌ខៀវ

**ខ- ផ្ទៃខាងមុខ ៖**

- **ផ្នែកកណ្តាល** ខាងស្តាំត្រូវបានរំលេចឡើងនូវព្រះឆាយាល័ក្ខណ៍មើលចំពីមុខ នៃ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់គ្រឿងព្រះមហាក្សត្រ ដែលផ្ទៃខាងក្រោយត្រូវបានតែងលំអដោយក្បាច់ចម្លាក់ជាប្រពៃណីក្នុងព្រះបរមរាជវាំងភ្នំពេញ ព្រមជាមួយអក្សរ "មួយម៉ឺនប្រាំពាន់រៀល" នៅខាងក្រោម ។ ខាងឆ្វេងមានលេខ "១៥០០០" នៅពីលើ ព្រមទាំងហត្ថលេខារបស់ទេសាភិបាលនិងអគ្គបេឡាខិតមកក្រោមមានរូបចម្លាក់នាគក្បាល ៧ នៅប្រាសាទអង្គរវត្ត និងមានបង្អួចផ្លារាងចតុកោណស្មើបញ្ឈរកែង ដែលមានសមាសធាតុជាប៉ូលីមើរនៅអមក្បែរនោះ ។

- **ផ្នែកខាងស្តាំ** ខាងលើមានអក្សរ "ធនាគារជាតិនៃកម្ពុជា" ខិតមកក្រោមមានលេខមាលាបោះពុម្ពដោយទឹកខ្មៅពីរពណ៌ គឺតួមាលានិងលេខ "15" បោះពុម្ពដោយទឹកខ្មៅពណ៌ក្រហម និងលេខ ៦ ខ្ទង់ទៀតបោះពុម្ពដោយទឹកខ្មៅពណ៌ខ្មៅ នៅពីក្រោមនោះមានលេខ "១៥០០០" និង



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

" 15000 " និងមានអក្សរ " អ្នកក្លែងក្រដាសប្រាក់នឹងត្រូវផ្តន្ទាទោសតាមច្បាប់ " នៅគែមខាងក្រោម ។ នៅគែមខាងស្តាំនៃក្រដាសប្រាក់ មានរូបភាពអង្គដៅចំណាំបោះពុម្ពតាមបន្ទាត់បញ្ឈរ ដែលឆ្លុះឃើញមានលេខ " 15000 " ។

- **ផ្នែកខាងឆ្វេង** ខាងលើមានរូបព្រះសង្ហារនៃព្រះរាជាណាចក្រកម្ពុជា និងមានលេខ " 15000 " ព្រាលៗបោះពុម្ពតាមបន្ទាត់បញ្ឈរនៅពីក្រោមនោះ ព្រមជាមួយបន្ទះហូឡូក្រាមទំហំ ១០មម កាត់ទទឹងផ្ទៃក្រដាសប្រាក់ពីលើដល់ក្រោម ។ នៅជ្រុងខាងក្រោមមានគំនូសបន្ទាត់សម្រាប់ផ្ទៀងផ្ទាត់ និងនិមិត្តសញ្ញាពិសេសសម្គាល់ប្រភេទប្រាក់សម្រាប់ជនពិការភ្នែក ។

**គ- <u>ផ្ទៃខាងខ្នង</u> ៖**

- **ផ្នែកកណ្តាល** ត្រូវបានរំលេចឡើងនូវ**ព្រះឆាយាល័ក្ខណ៍ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា រួមជាមួយព្រះវររាជបិតា និងព្រះវររាជមាតា ក្នុងព្រះរាជពិធីស្រោចស្រពព្រះសុគន្ធវារី និងមានអក្សរ " មួយម៉ឺនប្រាំពាន់រៀល " នៅពីក្រោម និងអក្សរ " Congratulations the 15th Anniversary of the Coronation of His Majesty Preah Bat Samdach Preah Boromneth NORODOM SIHAMONI ( 29 October 2004-29 October 2019 ) " នៅគែមក្រដាសប្រាក់ ។

- **ផ្នែកខាងស្តាំ** ត្រូវបានរំលេចឡើងនូវរូបវិមានឈ្នះឈ្នះ ព្រមទាំងរូបចម្លាក់ថ្ម ដំរីក្បាលបីមានស្លាប-គ្រុឌ-ហង្ស នៅជ្រុងទាំង ៤ នៃខឿនវិមានឈ្នះឈ្នះ និងមានបង្គួចផ្កាវាងចតុកោណស្មើបញ្ឈរកែងមានសមាសភាពជាប៉ូលីមើរ នៅផ្នែកខាងក្រោម ព្រមជាមួយខ្សែសុវត្ថិភាពទំហំ ៤មម នៅផ្នែកខាងឆ្វេង ។ នៅជ្រុងលើខាងស្តាំមានលេខ " 15000 " ដែលត្រូវបានបោះពុម្ពតាមបន្ទាត់បញ្ឈរ ។

- **ផ្នែកខាងឆ្វេង** ខាងលើមានអក្សរ " ធនាគារជាតិនៃកម្ពុជា " និងអក្សរ " NATIONAL BANK OF CAMBODIA " ខិតមកក្រោមមានចារឹកអក្សរ " អបអរសាទរខួប ១៥ ឆ្នាំ នៃការគ្រងរាជសម្បត្តិ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ( ២៩ តុលា ២០០៤ - ២៩ តុលា ២០១៩ ) " ព្រមទាំងលេខ " 2019 " និងលេខ " 15000 " នៅពីក្រោមនោះ ។ នៅគែមខាងឆ្វេងនៃក្រដាសប្រាក់មានរូបភាពអង្គដៅចំណាំ បោះពុម្ពតាមបន្ទាត់បញ្ឈរ ដែលឆ្លុះឃើញលេខ " 15000 " ។

ចាប់ពីថ្ងៃចេញប្រកាសនេះតទៅ ធនប័ត្រអនុស្សាវរីយ៍ប្រភេទ ១៥០០០ រៀល ត្រូវបានដាក់ឲ្យចរាចរទន្ទឹមគ្នាជាមួយនឹងធនប័ត្រជាតិប្រភេទផ្សេងៗទៀត ដែលត្រូវបានចេញផ្សាយកន្លងមក ។ សាធារណជនគ្រប់រូប ត្រូវពិនិត្យ-សម្គាល់ធនប័ត្រថ្មីនេះឲ្យបានច្បាស់លាស់ ដើម្បីជៀសវាងការភ័ន្តច្រឡំ ។

ថ្ងៃ ចន្ទ ៩ កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០១៩

**ទេសាភិបាល**

ជា_ចាន់តូ